# ភាពទៀងត្រង់ដ៏ផ្អែមល្ហែម

ដោយ ជេន ម៉ាកប្រាយដ៍

ផ្អែកទៅលើដំណើររឿងពិត

*« ប្រព្រឹត្តសេចក្ដីល្អតែប៉ុណ្ណោះ » ( កូរិនថូសទី ២ ១៣:៧ ) ។*

ម៉ាក់បាននិយាយថា « ម៉ាក់ត្រូវការកូនមើលថែប្អូន ។ ប៉ារបស់កូន និងម៉ាក់នឹងទៅជួយមនុស្សម្នាក់ដែលឈឺ » ។

ខ្ញុំបានងើយមុខមើលគាត់ពេលកំពុងជូតកម្រាលឥដ្ឋផ្ទះតូចរបស់យើង ហើយងក់ក្បាល ។ ម៉ាក់គឺជាប្រធានសមាគមន៍សង្គ្រោះ ហើយជារឿយៗគាត់បានទៅសួរសុខទុក្ខបងប្អូនស្រីនៅក្នុងវួដរបស់យើង ។

ម៉ាក់បាននិយាយទាំងថើបសក់ក្បាលខ្ញុំថា « អរគុណអាលីន ។ ចនកំពុងគេង ។ ហើយមានម្សៅធ្វើនំប៉័ងនៅលើតុ ។ សុំកុំប៉ះពាល់វា » ។

ខ្ញុំបានមើលម៉ាក់ និងប៉ាតាមមាត់ទ្វារ ពេលពួកគេជិះរទេះមានដំបូងទៅតាមផ្លូវដីហុយ ។ ខ្ញុំមានអារម្មណ៍មោទនភាពដែលម៉ាក់បានទុកចិត្តខ្ញុំ ។

ពេលខ្ញុំបោសសម្អាតផ្ទះបាយ ខ្ញុំបានឈប់ ហើយមើលទៅម្សៅធ្វើនំប៉័ងនោះ ។ ខ្ញុំពុំអាចទ្រាំនឹងរង់ចាំឲ្យម៉ាក់ធ្វើនំប៉័ងយប់នេះឡើយ ។ ជាទូទៅ យើងបរិភោគនំប៉័ងស្រស់ៗជាមួយដំណាប់ដែលយើងធ្វើ ។ ប៉ុន្តែយើងបានអស់ដំណាប់បីខែមកហើយ ។

ដំណាប់ ! គំនិតនេះបានធ្វើឲ្យខ្ញុំឃ្លានអ្វីមួយផ្អែមៗ ។ ខ្ញុំបានក្រឡេកមើលទៅក្រឡស្ករដែលនៅលើធ្នើរខ្ពស់ ។ ខ្ញុំដឹងថា ម៉ាក់បានទុកវាដើម្បីធ្វើដំណាប់បន្ថែមទៀត ។

ប៉ុន្តែពេលណាខ្ញុំគិតអំពីស្ករ នោះខ្ញុំកាន់តែឃ្លាន ។ ទីបំផុត ខ្ញុំបានទាញកៅអីដាក់ឡើងលើតុ ហើយឈោងយកវា ។ ម្រាមដៃរបស់ខ្ញុំស្ទើរតែប៉ះក្រឡស្ករនោះ ។ ខ្ញុំបានទាញវាមកក្បែរគែមធ្នើរ ។ . . .



បន្ទាប់មក ក្រឡនោះបានរអិលធ្លាក់ចុះពីធ្នើរ ។ ខ្ញុំបានព្យាយាមចាប់វា ប៉ុន្តែវាបានធ្លាក់ឮសំឡេងយ៉ាងខ្លាំងនៅចំកណ្ដាលម្សៅធ្វើនំប៉័ង ។ ស្ករបានខ្ចាយពេញលើនំប៉័ង និងតុ ព្រមទាំងលើកម្រាលឥដ្ឋផងដែរ ។

ខ្ញុំបានស្រែក « អ៊ូ អត់ទេ ! » វាបានធ្វើឲ្យប្អូនប្រុសខ្ញុំភ្ញាក់ ។ គាត់បានចាប់ផ្ដើមយំ ។ ខ្ញុំ ក៏ចង់យំដែរ ។ តើម៉ាក់នឹងនិយាយដូចម្ដេចអំពីភាពរញ៉េរញ៉ៃនេះ ?

បន្ទាប់ពីខ្ញុំបានលួងចនហើយ ខ្ញុំបានខំសម្អាតស្ករដែលខ្ចាយនោះ ។ ខ្ញុំបានទាញក្រឡនោះចេញពីម្សៅ ហើយលាងសម្អាតវា ។ ខ្ញុំបានបោសសម្អាតស្ករចេញពីតុ និងកម្រាលឥដ្ឋ ។ ប៉ុន្តែខ្ញុំពុំអាចធ្វើអ្វីមួយដើម្បីយកស្ករចេញពីម្សៅបានឡើយ ។

ខ្ញុំបានគិតពីការទុកក្រឡស្ករទៅលើធ្នើរវិញ ។ ប្រហែលជាម៉ាក់មិនចាំថា អស់ស្ករទេ ។ ប៉ុន្តែខ្ញុំដឹងថា ធ្វើបែបនេះពុំត្រូវទេ ។ ដូច្នេះខ្ញុំបានទុកក្រឡនេះនៅលើតុ ហើយរង់ចាំរហូតដល់ម៉ាក់ និងប៉ាត្រឡប់មកផ្ទះវិញ ។

ពេលពួកគាត់មកដល់ផ្ទះ ម៉ាក់បានឃើញក្រឡស្ករភ្លាម ។

ខ្ញុំបានដកដង្ហើមធំ ។ « កូនគ្រាន់តែចង់ភ្លក់រសជាតិស្ករ ! តែកូនបានប៉ះក្រឡស្ករធ្លាក់ចុះពីធ្នើរ ។ កូនបានព្យាយាមសម្អាតវា ប៉ុន្តែកូនពុំអាចយកស្ករចេញពីម្សៅធ្វើនំប៉័ងបានទេ » ។ ខ្ញុំបាននិយាយយ៉ាងលឿន ខណៈដែលខ្ញុំឱនមុខចុះទៅកម្រាលឥដ្ឋ ។

ម៉ាក់បាននៅស្ងៀមមួយសន្ទុះ ។

ខ្ញុំបាននិយាយខ្សឹបៗថា « ឲ្យកូនសុំទោស » ។

ម៉ាក់បានដកដង្ហើមធំ ។ គាត់បាននិយាយថា « អញ្ចឹងម៉ាក់គិតថា នំប៉័ងនឹងមានរសជាតិផ្អែមខ្លាំងហើយយប់នេះ ។ ខ្ញុំបានងើយមើលទៅគាត់ ។ គាត់បានញញឹមបន្តិចដាក់ខ្ញុំ ។ « អរគុណដែលកូនបានប្រាប់នូវអ្វីដែលបានកើតឡើង ។

ពេលយើងបរិភោគនំប៉័ងផ្អែមនាយប់នោះ ម៉ាក់ និងប៉ា ព្រមទាំងខ្ញុំបាននិយាយគ្នាអំពីភាពទៀងត្រង់ ។

ប៉ាបាននិយាយថា « យើងទាំងអស់គ្នាធ្វើខុសច្រើននៅក្នុងជីវិត ។ ប៉ុន្តែពេលយើងមានចិត្តទៀងត្រង់ ហើយព្យាយាមប្រែចិត្ត នោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវសព្វព្រះទ័យ ។ យើងនឹងមានពរជានិច្ចសម្រាប់ការមានចិត្តទៀងត្រង់—ទោះបីវាហាក់ដូចជាលំបាកនៅពេលដំបូងក្ដី » ។

ខ្ញុំនៅតែស្ដាយ ដែលខ្ញុំបានធ្វើឲ្យកំពប់ស្ករ ។ ខ្ញុំបានដឹងថា យើងប្រហែលជាគ្មានដំណាប់ច្រើនទេនាឆ្នាំនេះ ដោយសារតែកំហុសរបស់ខ្ញុំ ។ ប៉ុន្តែខ្ញុំរីករាយដែលខ្ញុំបាននិយាយការពិត ។ នោះគឺជាអារម្មណ៍ដ៏ផ្អែមល្ហែមមួយ ដែលទោះជាមានស្ករប៉ុន្មានក៏មិនអាចធ្វើឲ្យវាផ្អែមដូចនេះឡើយ ។●

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។*



« ការគោរពព្រះបញ្ញត្តិនាំមកនូវពរជ័យ គ្រប់ពេល ! ការរំលងព្រះបញ្ញត្តិនាំមកនូវការបាត់បង់ពរជ័យ គ្រប់ពេល ! »

ប្រធាន រ័សុល អិម ណិលសុន « ចូរបង្ហាញសេចក្ដីជំនឿអ្នក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៣០ ។